**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

**ក្រុមហ៊ុនហ្គ្រីនត្រេដ**

លេខ..០០៣.........កហត

ថ្ងៃ.សុក្រ..៤..រោច........ខែ.បុស្ស...ឆ្នាំរការ នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី..០៥..ខែ...មករា.....ឆ្នាំ ២០.១៨.

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈ ឆ្នាំ២០១៨

ក្រុមហ៊ុនហ្គ្រីនត្រេដ នៃក្រសួងពាណិជ្ជកម្ម សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល )ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា៖ **ក្រុមហ៊ុនហ្គ្រីនត្រេដ** នឹងដាក់អោយដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈ សម្រាប់ឆ្នាំ២០១៨ ។

ក្រុមហ៊ុនហ្គ្រីនត្រេដ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម **ក្រុមហ៊ុនហ្គ្រីនត្រេដ** ដែលមានអាសយដ្ឋានអាគារលេខ:៣០ ផ្លូវព្រែនគរ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទទាក់ទង( 012 979 302,012 911 698 ) ចាប់ពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង៩:០០នាទី ព្រឹក ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង ៩:០០នាទី ព្រឹក ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

**អគ្គនាយក**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ចាន់_សុខទី**

ចម្លងជូន៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ " ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "

-ឯកសារកាលប្បវត្តិ